Ottawa County Health Department

# រោគខាន់ស្លាក់ [DIPTHERIA]

### តើរោគខាន់ស្លាក់គឺជាអ្វី?

រោគខាន់ស្លាក់គឺជាជម្ងឺ បង្ករឡើងដោយមេរោគបាក់តេរីមួយ ដែលប៉ះពាល់ដល់អាមីដាល់ បំពង់ក ច្រមុះ ឬស្បែក ។

### តើរោគខាន់ស្លាក់ត្រូវបានឆ្លងយ៉ាងដូចម្តេច?

រោគខាន់ស្លាក់អាចចម្លងទៅអ្នកដទៃតាមរយៈ: ដំណក់ទឹកតូចៗ មកពីច្រមុះ បំពងក ស្បែក ភ្នែក និងដំបៅស្បែក របស់អ្នកមានមេរោគនេះ ។

### តើអាចមានរោគសញ្ញាអ្វីខ្លះ?

រោគសញ្ញាអាចមានរួមទាំង:

- ឈឺបំពង់ក
- ភ្នាសពណ៌ប្រផេះ នៅផ្នែកខាងក្រោយនៃបំពង់ក
- រងា
- ក្តៅខ្លួន
- ដុំសាច់ហើមនៅចំហៀងក
- ដំបៅស្បែក

### តើរោគខាន់ស្លាក់ត្រូវបានវិនិច្ឆ័យរោគយ៉ាងដូចម្តេច?

ដោយពិនិត្យ (មើលសំគាល់ភ្នាសពណ៌ប្រផេះ នៅផ្នែកខាងក្រោយនៃបំពង់ក) ហើយនិងការពិនិត្យផ្សេងៗ នៅក្នុងមន្ទីរពិសោធ ។

### តើរោគខាន់ស្លាក់ត្រូវបានព្យាបាលយ៉ាងដូចម្តេច?

ថ្នាំអង់ទីប៊ីយ៉ូទិក ហើយនិងថ្នាំបន្សាបរោគខាន់ស្លាក់ ។

### តើខ្ញុំអាចបង្ការរោគខាន់ស្លាក់បានយ៉ាងដូចម្តេច?

មានថ្នាំចាក់បង្ការរោគសម្រាប់រោគខាន់ស្លាក់ ។ ថ្នាំបង្ការរោគគួរតែចាក់នៅអាយុ 2, 4, 6 និង 15-18 ខែ ហើយរវាងអាយុ 4-6 ឆ្នាំ ។ ភាពស៊ាំថយចុះតាមពេលវេលា ដូច្នេះ ជាការសំខាន់ដែលជនពេញវ័យត្រូវចាក់ថ្នាំម្តងទៀតរាល់ 10 ឆ្នាំ ។

### សម្រាប់ព័ត៌មានបន្ថែមអំពីរោគខាន់ស្លាក:

Ottawa County Health Department
www.miOttawa.org
Medline Plus/National Institutes of Health
www.nlm.nih.gov/medlineplus/ency/article/001608.htm

12251 James St., Suite 400
Holland, MI 49424
ទូរស័ព្ទ: (616) 396-5266
ទូរសារ: (616) 393-5643
វិបសាយ: www.miOttawa.org